ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

លេខ......០៥៨........ កកន/សគល

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការជ្រើសរើសទីប្រឹក្សា ដើម្បីធ្វើសមាហរណកម្មគោលការណ៍ណែនាំស្តីពីការបញ្ជូន សម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ទៅក្នុងនីតិវិធីស្តង់ដារ (SOP) សម្រាប់ការពារកុមារ និងរៀបចំឯកសារបណ្តុះបណ្តាលស្តីពី អំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)**

ក្រសួងកិច្ចការនារី សូមជម្រាបជូនសាធារណៈជនទាំងបុរស និងស្ត្រី ជ្រាបថា ក្រសួងកិច្ចការនារីនឹងធ្វើការជ្រើសរើសទីប្រឹក្សា ឬអ្នកជំនាញ (ជាបុគ្គល) ដើម្បីធ្វើសមាហរណកម្មគោលការណ៍ណែនាំស្តីពីការបញ្ជូន សម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ទៅក្នុងនីតិវិធីស្តង់ដារ (SOP) សម្រាប់ការពារកុមារ និងរៀបចំឯកសារបណ្តុះបណ្តាលស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

## លក្ខខណ្ឌប្រគល់ភារកិច្ចសម្រាប់ទីប្រឹក្សាជាបុគ្គល

### ១. ស្ថានភាព

ក្នុងបរិការណ៍ដែលមនុស្សគ្រប់គ្នាប្រឈមនឹងឆ្លងជំងឺកូវីដ១៩ ក្នុងនោះ កុមារនិងស្ត្រីក៏កំពុងងាយរងគ្រោះរួចទៅហើយដោយសារតែពួកគេត្រូវបានផាត់ចេញពីឱកាសសង្គមសេដ្ឋកិច្ច ឬអ្នកដែលកំពុងធ្វើចំណាកស្រុក និង/ឬរស់នៅទីកន្លែងដែលមានមនុស្សម្នារស់នៅកកកុញ រឹតតែប្រឈមនឹងអំពើហិង្សាទៅទៀត ដូចជា ការមើលឃើញ និង/ឬការទទួលរងដោយផ្ទាល់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ជាដើម។[1] ស្ថានភាពបច្ចុប្បន្នបានបង្កការរំខានដល់ការផ្តល់សេវានិងបន្តដាក់សម្ពាធមកលើប្រព័ន្ធការពារនិងប្រព័ន្ធសុខាភិបាល ដែលដាក់កំហិតលើសមត្ថភាពរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យការពារកុមារ និង GBV ក្នុងការធានាឱ្យមានការបន្តផ្តល់សេវាប្រកបដោយគុណភាពដល់កុមារ និងក្មេងជំទង់ដែលរួចរស់ពីអំពើហិង្សា ដែលនេះតម្រូវឱ្យមានការ

[1] របាយការណ៍ស្តីពីការកើនឡើងនៅករណីអំពើហិង្សាលើស្ត្រីនៅកម្ពុជា ក៏ត្រូវបានថ្នាក់ដឹកនាំកិច្ចការនារីរបស់អាស៊ាន លើកឡើងកាលពីពេលថ្មីៗនេះផងដែរ៖ https://www.khmertimeskh.com/50925300/violence-against-women-on-the-rise-amid-pandemic/



ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

បង្កើនកិច្ចខិតខំប្រឹងប្រែង ស្វែងរកកម្លាំងផ្គួប សម្របសម្រួល ជំរុញការសហការ និងធ្វើសមាហរណកម្មសេវានានាបញ្ចូលគ្នា។

ក្នុងបរិបទបច្ចុប្បន្ននេះ មានភាពចាំបាច់បន្ទាន់ ដើម្បីពង្រឹងការអនុវត្តកម្មវិធី GBViE ដែលនៅបន្តទទួលបានថវិកាគាំទ្រមិនគ្រប់គ្រាន់ និងមានសមត្ថភាពនៅមានកម្រិត (មានភ្នាក់ងារសង្គមកិច្ចក្នុងខេត្តចំនួន ៣ ប៉ុណ្ណោះដែលបានទទួលការបណ្តុះបណ្តាលអំពីGBViEហើយបើតាមមតិត្រឡប់ដែលបានទទួលអំពីការបណ្តុះបណ្តាល រៀបចំឡើងកាលពីឆ្នាំមុន ភ្នាក់ងារសង្គមកិច្ច ត្រូវការការកសាងសមត្ថភាពបន្ថែម ដើម្បីឱ្យពួកគេអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះករណី GBV)។ ការគាំទ្រសម្រាប់ការងារ GBV អាចធ្វើឡើងបន្ថែមលើគំនិតផ្តួចផ្តើម និងធនធានដែលមានស្រាប់ ជាពិសេសកម្មវិធីផ្តល់ការណែនាំ អំពី GBV (GBV pocket guide app) យុទ្ធសាស្ត្រជាតិស្តីពីការផ្លាស់ប្តូរឥរិយាបថ និងយុទ្ធនាការ Cambodia PROTECT ដើម្បីការពារកុមារពីអំពើហិង្សា ការអភិវឌ្ឍ និងការរៀបចំកម្លាំង សេវាសង្គម ជាផ្លូវការ ឧបករណ៍គ្រប់គ្រងករណី Primero និងការរៀបចំនីតិវិធីស្តង់ដារ (SOP) សម្រាប់សេវាការពារកុមារ ដែលគេអាចភ្ជាប់ទំនាក់ទំនងឱ្យមានភាពប្រទាក់ក្រឡាគ្នា និងបន្តពង្រឹងគោលការណ៍ណែនាំ ស្តីពីការបញ្ជូនករណី GBV ដើម្បីឱ្យការឆ្លើយតបចំពោះករណីអំពើហិង្សាលើកុមារ និងអំពើហិង្សាលើស្ត្រីអាចធ្វើឡើងដោយប្រើប្រាស់អភិក្រមដែលកាន់តែមានការសម្របសម្រួលបានកាន់តែប្រសើរ។

## ២. លក្ខខណ្ឌប្រតិបត្តិ និងកិច្ចការលម្អិតដែលត្រូវធ្វើ៖

លក្ខខណ្ឌប្រតិបត្តិ និងកិច្ចការលម្អិត ដើម្បីធ្វើសមាហរណកម្មគោលការណ៍ណែនាំស្តីពីការបញ្ជូនសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) ទៅក្នុងនីតិវិធីស្តង់ដារ(SOP) សម្រាប់ការពារកុមារ និងរៀបចំឯកសារបណ្តុះបណ្តាលស្តីពី GBV៖

**លទ្ធផលការងារទី ១៖ ធ្វើសមាហរណកម្មគោលការណ៍ណែនាំ ស្តីពីបញ្ជូនសម្រាប់ករណី GBV ទៅក្នុងនីតិវិធីស្តង់ដារ ស្តីពីការការពារកុមារ (SOP) និង Primero ដែលជាប្រព័ន្ធគ្រប់គ្រងករណីបែបឌីជីថល៖**

- រៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយតួអង្គពាក់ព័ន្ធ ដើម្បីឈ្វេងយល់ពីគោលការណ៍ណែនាំស្តីពីការបញ្ជូននាពេលបច្ចុប្បន្នដែលត្រូវបានប្រើប្រាស់សម្រាប់ទាំងករណី GBV ទាំងករណីការពារកុមារ ជាអាទិ៍ ជាមួយតំណាងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធនានា UNICEF, UNFPA, និង UN Women។
- រៀបចំពង្រៀងក្របខ័ណ្ឌ ដើម្បីបង្ហាញពីរបៀបដែលគោលការណ៍ណែនាំស្តីពីការបញ្ជូនសម្រាប់ករណី GBV ដែលកំពុងមាននាពេលបច្ចុប្បន្នអាចធ្វើសមាហរណកម្មបញ្ចូលទៅក្នុង SOP ស្តីពីការការពារកុមារ ក៏ដូចជា

របៀបដែលគោលការណ៍ណែនាំស្តីពីការបញ្ជូនសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) អាចភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រព័ន្ធ Primero ដែលជាប្រព័ន្ធគ្រប់គ្រងករណីបែបឌីជីថល។

- សម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ របស់រដ្ឋាភិបាល ដូចជា UNICEF, UNFPA និង UN Women អង្គការសង្គមស៊ីវិលសំខាន់ៗ តំណាងយុវជនជំទង់ ដើម្បីពិនិត្យ និងផ្តល់ជាតុចូលដល់ពង្រៀងក្របខ័ណ្ឌនេះ។
- បញ្ចូលជាតុចូលទៅក្នុងក្របខ័ណ្ឌ និងដាក់ជូនក្រសួងកិច្ចការនារី ដើម្បីផ្តល់ការអនុម័តចុងក្រោយ។

**លទ្ធផលការងារទី ២៖ រៀបចំឯកសារបណ្តុះបណ្តាលស្តីពី GBV ដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិ ដែលប្រើប្រាស់សម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម**

- ប្រមូល និងពិនិត្យឯកសារដែលមានស្រាប់របស់ក្រសួងពាក់ព័ន្ធ និងធ្វើការកំណត់ ឬជ្រើសរើសប្រធានបទសំខាន់ៗ ដែលត្រូវដាក់ជូនក្រុមទីប្រឹក្សា។
- ពិនិត្យលើឯកសារពាក់ព័ន្ធ ដើម្បីកំណត់រកឯកសារបណ្តុះបណ្តាល ដែលមានស្រាប់ស្តីពី GBV និងប្រធានបទពាក់ព័ន្ធដទៃទៀត ដូចជាការការពារកុមារជាដើម។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ ដើម្បីឈ្វេងយល់ពីស្ថានភាពបច្ចុប្បន្ននៃការបណ្តុះបណ្តាលនិងតម្រូវការសមត្ថភាពរបស់កម្លាំងសេវាសង្គម ជាអាទិ៍ជាមួយតំណាងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា និងអ្នកពាក់ព័ន្ធ UNICEF, UNFPA, និង UN Women។
- ផ្អែកតាមកិច្ចពិគ្រោះយោបល់ទាំងនេះ រៀបចំមាតិកា ប្រធានបទដែលត្រូវបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាល និងឯកសារដែលត្រូវប្រើប្រាស់ និងដាក់ជូនក្រសួងកិច្ចការនារី ដើម្បីពិនិត្យ និងផ្តល់យោបល់។
- ក្រោយពីបានបញ្ចូលយោបល់ ដែលបានពីក្រសួងកិច្ចការនារីរួច រៀបចំកញ្ចប់បណ្តុះបណ្តាល និងសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗរបស់រដ្ឋាភិបាល ព្រមទាំង UNICEF, UNFPA, និង UN Women ដើម្បីពិនិត្យ និងផ្តល់ជាតុចូលដល់កញ្ចប់បណ្តុះបណ្តាលនេះ។
- បញ្ចូលជាតុចូលទៅក្នុងកញ្ចប់បណ្តុះបណ្តាល និងដាក់ជូនក្រសួងកិច្ចការនារី ដើម្បីអនុម័តចុងក្រោយ។

## ៣. រយៈពេលនៃកិច្ចព្រមព្រៀង៖ ពីថ្ងៃទី០១ ខែកុម្ភៈ ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២

## ៤. លទ្ធផលរំពឹងទុក

- ផ្តល់នូវក្របខ័ណ្ឌសម្រាប់ធ្វើសមាហរណកម្មគោលការណ៍ណែនាំ ស្តីពីការបញ្ជូនសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាមានអាសន្ន (GBViE) ទៅក្នុងនីតិវិធីរួមស្តីពីការការពារកុមារ និងប្រព័ន្ធ

Primero ដែលជាប្រព័ន្ធគ្រប់គ្រងករណីបែបឌីជីថល ដែលបានទទួលការយល់ព្រម និងឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាល។

- ផ្តល់នូវឯកសារបណ្តុះបណ្តាលស្តីពី GBViE ដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិ ដែលប្រើប្រាស់សម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ដែលត្រូវបានយល់ព្រម និងឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់របស់រដ្ឋាភិបាល។
- រៀបចំចងក្រងរបាយការណ៍តាមសកម្មភាពនីមួយៗ។

## ៥. លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំរបាយការណ៍៖

- រាល់ឯកសារការងារ និងផលិតផលចុងក្រោយទាំងអស់ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវរៀបចំប្រកបដោយគុណភាពខ្ពស់ ក្នុងទម្រង់ដែលងាយស្រួលយល់។ កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារនីមួយៗត្រូវបានរៀបរាប់លម្អិតនៅក្នុង "ចំណុចទី ២ លក្ខខណ្ឌប្រតិបត្តិ"។ ក្រសួងកិច្ចការនារី គឺជាស្ថាប័នដែលត្រូវទទួលរបាយការណ៍ទាំងអស់នេះ។

## ៦. ការទូទាត់៖

- ការទូទាត់ ៥0% បន្ទាប់ពីបានបញ្ចប់លទ្ធផលការងារដូចតទៅ ក្នុងកម្រិតជាទីពេញចិត្ត (១)៖ ការដាក់ឯកសារស្តីពីក្របខ័ណ្ឌសម្រាប់ធ្វើសមាហរណកម្មគោលការណ៍ណែនាំស្តីពីការបញ្ជូនសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) ទៅក្នុងស្តង់ដារនីតិវិធីរួមស្តីពីការការពារកុមារ និងប្រព័ន្ធ Primero ដែលជាប្រព័ន្ធគ្រប់គ្រងករណីបែបឌីជីថល ដែលបានទទួលការយល់ព្រម និងឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាល។
- ការទូទាត់ ៥0% បន្ទាប់ពីបានបញ្ចប់លទ្ធផលការងារដូចតទៅ ក្នុងកម្រិតជាទីពេញចិត្ត (២)៖ ការដាក់ឯកសារបណ្តុះបណ្តាលស្តីពី GBV ដែលត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិ ដែលប្រើប្រាស់សម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គមដែលត្រូវបានយល់ព្រម និងឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់របស់រដ្ឋាភិបាល។

## ៧. គុណវុឌ្ឍិ ឬចំណេះដឹង/បទពិសោធន៍ឯកទេសដែលចាំបាច់ត្រូវមាន៖

- បរិញ្ញាបត្រ ឬសញ្ញាបត្រកម្រិតខ្ពស់ពីសាកលវិទ្យាល័យ ខាងជំនាញណាមួយក្នុងចំណោមជំនាញទាំងនេះ ដូចជា ជំនាញសង្គមកិច្ច យេនឌ័រ សិទ្ធិមនុស្ស ច្បាប់ ចិត្តវិទ្យា សុខភាពផ្លូវភេទនិងបន្តពូជ ឬជំនាញពាក់ព័ន្ធណាមួយទៀត។

- ជំនាញសម្របសម្រួល និងទំនាក់ទំនង ហើយនិងជំនាញអន្តរបុគ្គលស្ទាត់ជំនាញ ព្រមទាំងធ្លាប់ទទួលបានជោគជ័យក្នុងការសម្របសម្រួលដំណើរការអន្តរស្ថាប័ន ដើម្បីសម្រេចគោលដៅរួម។
- បទពិសោធន៍ក្នុងការអនុវត្តកម្មវិធីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាមានអាសន្ន (Gender-Based Violence in Emergency-GBViE) យ៉ាងហោចណាស់ ៥ ឆ្នាំជាមួយអង្គការសហប្រជាជាតិ ឬ អង្គការក្រៅ ឬរដ្ឋាភិបាលជាពិសេសក្នុងស្ថានភាពគ្រាមានអាសន្ន។
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍឯកសារបណ្តុះបណ្តាល និងកសាងសមត្ថភាពអំពីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រាមានអាសន្ន។
- មានបទពិសោធន៍ដឹកនាំដំណើរការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ (រដ្ឋាភិបាល) សង្គមស៊ីវិល អង្គការដៃគូអភិវឌ្ឍ អង្គការសហប្រជាជាតិ និងស្ថាប័នដទៃទៀត។
- មានចំណេះដឹង និងយល់ពីបរិបទរបស់ប្រទេសកម្ពុជា
- មានបទពិសោធន៍ធ្វើការងារជាមួយរដ្ឋាភិបាល
- ចេះភាសាអង់គ្លេស និងភាសាខ្មែរស្ទាត់ជំនាញ

**៨. ស្ថាប័នគ្រប់គ្រងការអនុវត្តកិច្ចសន្យា៖** ក្រសួងកិច្ចការនារី

- អ្នកជំនាញដែលចាប់អារម្មណ៍ចំពោះការសិក្សានេះ អាចផ្ញើ CV និងលិខិតអមទៅកាន់ក្រសួងកិច្ចការនារី តាមរយៈអ៊ីមែល sochetra.nhean@yahoo.com និង sineth_sar@yahoo.com ឱ្យបានមុនថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២។ សម្រាប់បេក្ខជនដែលជាប់ក្នុងសម្រង់បញ្ជីខ្លី ក្រុមការងារនឹងទំនាក់ទំនងទៅវិញ។

ថ្ងៃ......................... ខែ ............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី...២១... ខែមករា ឆ្នាំ ២០២២

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជាប្រធានគម្រោង**

**ហ៊ូ សាមិត្ត**

<u>ចម្លងជូន</u>

.អង្គការយូនីសេហ្វ

.ឯកសារកាលប្បវត្តិ